ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៤០ សរណ ធទឧ

# សេចក្ដីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត តាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា នៅរសៀលថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៤ នេះ ព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្ដើមទទួលរងឥទ្ធិពលពីខ្យល់មូសុងនិរតីខ្លាំង ។ ស្ថានភាពអាកាសធាតុបែបនេះនឹងធ្វើឱ្យ :

១- ផ្ទៃសមុទ្រកម្ពុជា : ផ្ទៃមេឃនៅតំបន់លំហសមុទ្រកម្ពុជា នឹងមានពពកមីរដេរដាស មានភ្លៀងធ្លាក់ច្រើន លាយឡំជាមួយនឹងផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ខ្លាំង ។ រលកសមុទ្រមានកំពស់ពី 1,00 - 2,50 ម៉ែត្រ ។

២- តំបន់ឆ្នេរសមុទ្រ : ផ្ទៃមេឃនៅតំបន់ឆ្នេរសមុទ្រនៃខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត នឹងមានពពកច្រើនដេរដាស មានភ្លៀងធ្លាក់ពីមធ្យមទៅច្រើន លាយឡំជាមួយនឹងផ្គរ រន្ទះ និងមានខ្យល់កន្ត្រាក់ខ្លាំង ។

យោងតាមការព្យាករណ៍ស្ថានភាពអាកាសធាតុខាងលើនេះ សូមសាធារណជន ពិសេសបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរតាមសមុទ្រទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងត្រូវបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុត ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ។

បាតុភូតនេះ មានឥទ្ធិពលលើតំបន់ផ្ទៃសមុទ្រ និងតំបន់ឆ្នេរសមុទ្រកម្ពុជា ចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៤ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh